# ការធ្វើតេស្ត និងការព្យាបាល៖ ជំងឺរលាកថ្លើមប្រភេទ B

មធ្យោបាយតែមួយគត់ដើម្បីឱ្យដឹងថា អ្នកមានជំងឺរលាកថ្លើមប្រភេទ B ឬអត់ គឺតាមរយៈការធ្វើតេស្តឈាម។ នេះអាចធ្វើបានដោយវេជ្ជបណ្ឌិតព្យាបាលរោគទូទៅ (GP)។ ការធ្វើតេស្តឈាម នឹងប្រាប់អ្នកថាតើអ្នកធ្លាប់បានប៉ះពាល់នឹងជំងឺរលាកថ្លើមប្រភេទ Bហើយប្រព័ន្ធភាពស៊ាំរបស់អ្នកបានសម្អាតមេរោគដែរឬអត់ ថាតើអ្នកបានចាក់វ៉ាក់សាំង ហើយអ្នកកំពុងមានជំងឺរលាកថ្លើមប្រភេទ B នាពេលបច្ចុប្បន្នឬអត់។

ជំងឺរលាកថ្លើមប្រភេទ B អាចបណ្តាលឱ្យខូចខាតអស់រយៈពេលយូរ មុននឹងអ្នកជំងឺបង្ហាញរោគសញ្ញាណាមួយ។ អ្នកមិនអាចដឹងបានថា អ្នកមានជំងឺរលាកថ្លើមប្រភេទ B ដោយផ្អែកលើរោគសញ្ញាតែប៉ុណ្ណោះនោះទេ។

ប្រសិនបើអ្នកមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ការទៅពិនិត្យសុខភាពឱ្យបានទៀងទាត់គឺសំខាន់។ ទាំងនេះរួមមានការធ្វើតេស្តឈាម ហើយជាញឹកញាប់ការធ្វើអេកូថ្លើម។ ទាំងនេះនឹងបង្ហាញពីដំណាក់កាលមួយណានៃការឆ្លងមេរោគដែលអ្នកស្ថិតនៅ ថាតើថ្លើមរបស់អ្នកមានសុខភាពល្អយ៉ាងណា ហើយថាតើអ្នកត្រូវការថ្នាំព្យាបាលឬអត់។ វេជ្ជបណ្ឌិតរបស់អ្នកនឹងពិគ្រោះជាមួយអ្នក ថាតើអ្នកត្រូវការធ្វើតេស្តញឹកញាប់ប៉ុណ្ណាដែរ។

មិនមែនមនុស្សគ្រប់គ្នាត្រូវការថ្នាំព្យាបាលនោះទេ ប៉ុន្តែការពិនិត្យជាប្រចាំ គឺមានសារសំខាន់ដើម្បីពិនិត្យអំពីរឿងនេះ។

ប្រសិនបើការធ្វើតេស្តបង្ហាញថាអ្នកត្រូវការការព្យាបាល អ្នកនឹងត្រូវលេបថ្នាំព្យាបាលជាប្រចាំ។ ថ្នាំព្យាបាលនឹងមិនព្យាបាលជំងឺរលាកថ្លើមប្រភេទ B នោះទេ ប៉ុន្តែវានឹងកាត់បន្ថយហានិភ័យនៃការខូចថ្លើម ការខ្សោយថ្លើម និងជំងឺមហារីកថ្លើម។

ថ្នាំព្យាបាលទូទៅពីរគឺ Entecavir និង Tenofovir។

LiverWELL Incorporating HEPATITIS VICTORIA
GILEAD Supported by a grant from Gilead Sciences